ធ្វើឱ្យ Minnesota #1 មានការចូលរួមពីអ្នកបោះឆ្នោត និងជួយកាត់បន្ថយការរីករាលដាលជំងឺកូវីដ 19!

ពលរដ្ឋ Minnesota កំពុងធ្វើកិច្ចការរួមគ្នាដើម្បីរក្សាសុវត្ថិភាព និងសុខភាពរបស់គ្នាទៅវិញទៅមក។ នៅក្នុងឆ្នាំ2020 ដែលមានន័យថា ជាការបោះឆ្នោតពីផ្ទះ! នៅរដ្ឋ Minnesota អ្នកបោះឆ្នោតពេញសិទ្ធិ អាចជ្រើសរើសបោះឆ្នោតពីផ្ទះតាមរយៈការស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកមិនបានចូលរួមដោយផ្ទាល់។ អ្នកអាចស្នើសុំសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសកលនៅថ្ងៃទី03 ខែវិច្ឆិកា ឆ្នាំ2020 ខាងមុខនេះ។

- អ្នកទទួលបានលិខិតនេះដោយសារអ្នកគឺជាអ្នកបោះឆ្នោត Minnesota ដែលបានចុះឈ្មោះ។
- វិធីល្អបំផុតនៅក្នុងការស្នើសុំសន្លឹកឆ្នោតរបស់អ្នក គឺធ្វើឡើងតាមអនឡាញ www.mnvotes.org។
- ប្រសិនបើអ្នកបានដាក់ទម្រង់ស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកមិនបានចូលរួមដោយផ្ទាល់រួចហើយ សូមកុំដាក់បញ្ជូនម្ដងទៀត។

សូមមើលវេបសាយត៍ Visit www.mnvotes.org ឬទូរស័ព្ទទៅលេខ 1-877-600-VOTE សម្រាប់ព័ត៌មានបន្ថែម។

ដំណាក់កាលនៃការបោះឆ្នោតពីផ្ទះ

1. ដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោតសកលថ្ងៃទី03 ខែវិច្ឆិកា នៅ Minnesota អ្នកត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ។
អ្នកអាចស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកមិនបានចូលរួមដោយផ្ទាល់ ពេលដែលធ្វើការចុះឈ្មោះបោះឆ្នោត។
សូមពិនិត្យមើលការចុះឈ្មោះបោះឆ្នោតរបស់អ្នកតាមអនឡាញ www.mnvotes.org.

2. ធ្វើការស្នើសុំសន្លឹកឆ្នោតតាមអនឡាញ តាម mnvotes.org.

3. ប្រសិនបើអ្នកពុំមានសេវាអ៊ីនធឺណិត ឬប្រសិនបើអ្នកចង់ផ្ញើទម្រង់ត្រឡប់ទៅវិញតាមសេវាផ្ញើសំបុត្រ អ្នកអាចបំពេញទម្រង់ស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកមិនបានចូលរួមដោយផ្ទាល់ ដែលភ្ជាប់មកជាមួយ រួចត្រូវចុះហត្ថលេខា និងដាក់កាលបរិច្ឆេទ។

4. ប្រសិនបើអ្នកផ្ញើទម្រង់ជាក្រដាស ត្រូវផ្ញើទម្រង់នោះឱ្យបានឆាប់តាមដែលអាចធ្វើបាន ដើម្បីឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់ទៅអ្នកវិញ។ តម្លៃប្រៃសណីយ៍ត្រូវបានបង់ប្រាក់រួចហើយ អ្នកពុំចាំបាច់បិទតែមឡើយ! ទីកន្លែងភាគច្រើនចាប់ផ្ដើមផ្ញើសន្លឹកឆ្នោតចេញ រយៈពេលប្រហែល 6 សប្ដាហ៍មុនថ្ងៃបោះឆ្នោត។

5. សូមអនុវត្តតាមការណែនាំដើម្បីធ្វើការបោះឆ្នោត រួចផ្ញើត្រឡប់សន្លឹករបស់អ្នកមកវិញនៅពេលអ្នកបានទទួល តាមការផ្ញើសំបុត្រ។

6. តាមដានស្ថានភាពសន្លឹកឆ្នោតរបស់អ្នក រួចបញ្ជាក់ថា សន្លឹកឆ្នោតនោះត្រូវបានទទួល និងទទួលយកតាមវេបសាយត៍ mnvotes.org។

អ្នកបោះឆ្នោតពេញសិទ្ធិត្រូវបានលើកទឹកចិត្តឱ្យបោះឆ្នោតពីផ្ទះ ប៉ុន្តែកន្លែងបោះឆ្នោតនឹងបើកនៅថ្ងៃបោះឆ្នោតសម្រាប់អ្នកដែលត្រូវការ ឬចង់បោះឆ្នោតដោយផ្ទាល់។